# ឧម្មាទន្តីជាតក

## (ស្ត្រីដែលធ្វើឲ្យបុរសឆ្កួត)



**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*ដឹកនាំប្រែដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង** **ព.ស. ២៥៦២**



សាធុ ធម្មរុចី រាជា, សាធុ បញ្ញាណវា នរោ;
សាធុ មិត្តានមទ្ទុព្ភោ, បាបស្សាករណំ សុខំ

ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ទើបល្អ
ជនមានប្រាជ្ញាទើបល្អ ការមិនប្រទូស្តមិត្ត
ទើបល្អ កិរិយាមិនធ្វើបាបទើបសុខ

# ឧម្មាទន្តីជាតក

ព្រះសាស្តា កាលស្តេចគង់វត្តជេតពន ទ្រង់ប្រារព្ធ**ឧក្កណ្ឋិតភិក្ខុ** (ភិក្ខុអផ្សុកចង់សឹក) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **និវេសនំ កោស្ស-ធុរំ សុណន្ទា** ដូច្នេះជាដើម ។

បានឮមកថា ថ្ងៃមួយ ភិក្ខុនោះទៅបិណ្ឌបាត បានក្រឡេកមើលស្ត្រីមួយរូប ដែលប្រដាប់តាក់តែងដោយគ្រឿងអលង្ការ ទ្រទ្រង់រូបដ៏ឧត្តម ក៏មានចិត្តប្រតិព័ទ្ធ មិនអាចនឹងដកចិត្តបានឡើយ ទើបត្រឡប់មកកាន់វត្តវិញ ចាប់ពីពេលនោះមក លោករសាប់រសល់ដោយរាគៈ ហាក់ដូចជាត្រូវមុត ដោយកូនសរមានចំណែកដូចម្រឹគផ្អើល ទៅជាស្គាំងស្គម មានខ្លួនរវាមដោយសរសៃ ជារោគលឿងស្លេកស្លាំង មិនត្រេកអរ មិនមានចិត្តរីករាយ សូម្បីតែក្នុងឥរិយាបថមួយលះបង់វត្តទាំងឡាយ មានអាចរិយវត្តជាដើម នៅ

ដោយប្រាសចាកការប្រកបដោយឧទ្ទេស បរិបុច្ឆា និង កម្មដ្ឋាន ។ ភិក្ខុនោះ ត្រូវភិក្ខុជាសម្លាញ់សួរថា ម្នាល អាវុសោ កាលមុន អ្នកមានឥន្ទ្រិយស្រគត់ស្រគំ មាន សម្បុរមុខផូរផង់ តែឥឡូវនេះ អ្នកមិនជាយ៉ាងនោះ តើ ព្រោះហេតុអ្វី ? ក៏ពោលថា ម្នាលអាវុសោទាំងឡាយ ព្រោះខ្ញុំមិនត្រេកអរ ។

លំដាប់នោះ ភិក្ខុទាំងនោះ ពោលនឹងលោកថា ម្នាលអាវុសោ អ្នកចូរត្រេកអរនឹងសាសនាទៅ ឈ្មោះ ថា ការកើតឡើងនៃព្រះពុទ្ធ ជារបស់កម្រ ការស្តាប់ ព្រះសទ្ធម្ម និងការបានចំពោះអត្តភាពជាមនុស្ស ក៏ជា របស់ក្រ អ្នកបានអត្តភាពជាមនុស្សហើយ កាលប្រាថ្នា ការធ្វើទីបំផុតនៃទុក្ខ អ្នកបានលះបង់ញាតិជន ដែល មានមុខទទឹកដោយទឹកភ្នែក បួសដោយសទ្ធា ព្រោះ ហេតុអ្វី បានជាអ្នកលុះក្នុងអំណាចកិលេស ឈ្មោះថា កិលេសនេះ ជាសាធារណៈដល់ជនពាលទាំងពួង រាប់ ចាប់ពីជន្ទេនទៅ កិលេសទាំងឡាយនោះ ជាទីតាំងនៃ

វត្ថុកាម កាមទាំងឡាយនោះ មានសេចក្ដីត្រេកអរតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចិត្តច្រើន ទោសក្នុងកាមទាំងនោះមានច្រើន ។ (សេចក្ដីឧបមាទោសរបស់កាម មាន ១១ យ៉ាង គឺ)

**១. អដ្ឋិកង្កលូបមា កាមា** កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង

**២. មំសបេសូបមា កាមា** កាមទាំងឡាយមានឧបមាដោយដុំសាច់

**៣. តិណុក្កូបមា កាមា** កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើពីស្មៅ

**៤. អង្គារកាសូបមា កាមា** កាមទាំងឡាយមានឧបមាដោយរណ្ដៅរងើកភ្លើង

៥. **សុបិនកូបមា គាថា** *កាមទាំងឡាយមាន ឧបមាដោយអ្នកយល់សប្តិ*

៦. **យាចិតកូបមា គាថា** *កាមទាំងឡាយមាន ឧបមាដោយរបស់ដែលខ្ចីគេ*

៧. **រុក្ខផលូបមា គាថា** *កាមទាំងឡាយមានឧបមា ដោយផ្លែឈើ*

៨. **អសិសូនូបមា គាថា** *កាមទាំងឡាយមាន ឧបមាដោយកាំបិតនឹងជ្រញ់*

៩. **សត្តិសូលូបមា គាថា** *កាមទាំងឡាយមាន ឧបមាដោយលំពែងនឹងដែកស្រួច*

១០. **សប្បសិរូបមា គាថា** *កាមទាំងឡាយមាន ឧបមាដោយក្បាលពស់*

## ១១. អគ្គិក្ខន្ធូបមា កាមា *កាមទាំងឡាយមានឧបមាដោយគំនរភ្លើង*

*អ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលមានសភាពបែបនេះ បែរជាទៅលុះក្នុងអំណាចនៃកិលេស ដែលជាធម្មជាតធ្វើអំពើមិនជាប្រយោជន៍ ភិក្ខុទាំងឡាយឲ្យឱវាទដូច្នេះហើយ កាលមិនអាចនឹងឲ្យលោកកាន់យកពាក្យទូន្មានរបស់ខ្លួនបាន ទើបនាំភិក្ខុនោះ ទៅកាន់សម្នាក់ព្រះសាស្ដា ក្នុងធម្មសភា ។ កាលព្រះពុទ្ធត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំភិក្ខុដែលមិនប្រាថ្នានឹងមក ដើម្បីអ្វី ? ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ភិក្ខុនេះអផ្សុកចង់សឹក ។ ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកចង់សឹក ពិតមែនឬ ? ភិក្ខុនោះទូលថា ពិតមែនហើយ ព្រះអង្គ ។ ព្រះពុទ្ធត្រាស់ថា ម្នាលភិក្ខុបោរាណបណ្ឌិតទាំងឡាយ សូម្បីសោយរាជសម្បត្តិ ក៏*

មិនលុះ ក្នុងអំណាចនៃកិលេស ដែលកើតឡើងដែរ បានហាមឃាត់ចិត្ត មិនធ្វើកម្មមិនសមគួរឡើយ ដូច្នេះ ហើយ ទ្រង់នាំយកអតីតនិទានមកថា

ក្នុងអតីតកាលដ៏យូរលង់ណាស់មកហើយ ព្រះរាជាព្រះនាម **សិវិ** សោយរាជសម្បត្តិ ក្នុងអរិដ្ឋបុរនគរ ក្នុងដែនសិវិ ។ ព្រះពោធិសត្វកើតក្នុងផ្ទៃអគ្គមហេសី របស់ព្រះរាជានោះ (កាលប្រសូតហើយ) ពពួកញាតិ ថ្វាយព្រះនាមព្រះពោធិសត្វថា **សិវិកុមារ** ។ សូម្បីបុត្រ របស់សេនាបតីក៏បានកើតហើយ ពួកញាតិដាក់ឈ្មោះ ឲ្យគេថា **អភិបារកៈ** ។ កុមារទាំងពីរនោះ បានជា សម្លាញ់នឹងគ្នា កាលចម្រើនវ័យធំ ជាអ្នកមានអាយុ ១៦ ឆ្នាំ បានទៅកាន់នគរតក្កសិលា សិក្សារៀនសូត្រ សិល្បសាស្ត្រ រួចត្រឡប់មក ។ ព្រះរាជាប្រគល់រាជ សម្បត្តិដល់ព្រះរាជបុត្រ ។ ព្រះរាជាថ្មីបានតែងតាំង អភិបារកៈ ឲ្យជាសេនាបតី ទ្រង់សោយរាជសម្បត្តិ ប្រកបដោយធម៌ ។

នៅក្នុងនគរនោះ មានធីតារបស់ **តិរិដិវច្ឆសេដ្ឋី** ដែលមានទ្រព្យ ៨០ កោដិ នាងជាស្ត្រីទ្រទ្រង់រូបដ៏ឧត្តម ដល់ព្រមដោយភាពស្អាត និងលក្ខណៈល្អ ក្នុងថ្ងៃដាក់ឈ្មោះឲ្យនាង ពួកញាតិក៏បានដាក់ឈ្មោះនាងថា **ឧម្មាទន្តី** ។ នាងឧម្មាទន្តី កាលមានអាយុ ១៦ ឆ្នាំ មានពណ៌សម្បុរកន្លងលើសពួកមនុស្ស មានរូបល្អដ៏ក្រៃលែង ហាក់បីដូចជា ទេពអប្សរ មានរូបគួរពេចពិលរមិលមើល គួជាទីជ្រះថ្លា ដល់ព្រមដោយពណ៌សម្បុរ និងរាងរៅ ដ៏ស្រស់ស្អាត ។ បុថុជ្ជនទាំងឡាយណាៗ ឃើញនាងឧម្មាទន្តីនោះ បុថុជ្ជននោះៗ មិនអាចនឹងតាំងក្នុងសភាពរបស់ខ្លួនឡើយ ទៅជាមនុស្សវង្វេង ដោយការវង្វេងនៃកិលេស ហាក់ដូចជា មនុស្សវង្វេងព្រោះផឹកសុរា មិនអាចតាំងសតិបានឡើយ ។

តិរិដិវច្ឆសេដ្ឋីជាបិតា របស់នាង ចូលគាល់ព្រះរាជា ទូលថា បពិត្រព្រះសម្មតិទេព ឥត្ថិរតនៈកើត

ឡើងក្នុងផ្ទះ របស់ទូលព្រះបង្គំ ឥត្ថិរតនៈនោះសមគួរ ដល់ព្រះរាជាប៉ុណ្ណោះ សូមទ្រង់បញ្ជូនពួកព្រាហ្មណ៍ អ្នកពោលនូវលក្ខណៈ ឲ្យទៅពិនិត្យមើល ឥត្ថិរតនៈ នោះ ព្រះអង្គចូរធ្វើតាមសេចក្ដីពេញព្រះហឫទ័យចុះ ។ ព្រះរាជាទទួលថា ល្អ ហើយទ្រង់បញ្ជូនពួកព្រាហ្មណ៍ ទៅ ។ ព្រាហ្មណ៍ទាំងនោះទៅកាន់ផ្ទះសេដ្ឋី ធ្វើការ រាប់អានដោយសក្ការៈដែលខ្លួនគប្បីធ្វើ និងបរិភោគ បាយបាយាស ។ ក្នុងខណៈ នាងឧម្មាទន្តីប្រដាប់ តាក់តែង ដោយគ្រឿងអលង្ការទាំងពួង ហើយទៅកាន់ សម្នាក់ព្រាហ្មណ៍ទាំងនោះ ។ ពួកព្រាហ្មណ៍ឃើញ នាងឧម្មាទន្តីហើយ មិនអាចនឹងតាំងសតិបាន ទៅជា មនុស្សវង្វេង ដោយការវង្វេងព្រោះកិលេស មិនដឹង ភាពជាអ្នកធ្វើភោជនឲ្យប្លែករបស់ខ្លួន ។ ព្រាហ្មណ៍ខ្លះ កាន់យកពំនូតបាយ មកដាក់លើក្បាលដោយសម្គាល់ ថា យើងនឹងបរិភោគ, ព្រាហ្មណ៍ខ្លះយកដុំបាយមក

ក្នុងចន្លោះភ្លៀក, ព្រាហ្មណ៍វាយជញ្ជាំង ពួកព្រាហ្មណ៍ទាំងអស់ក៏ទៅជាមនុស្សឆ្កួត ។

នាងឧម្មាទន្តី ឃើញព្រាហ្មណ៍ទាំងនោះហើយ ក៏ពោលថា បានឮថា ព្រាហ្មណ៍ទាំងនេះ មកពិនិត្យមើលលក្ខណៈ របស់យើង អ្នកទាំងឡាយចូរចាប់កព្រាហ្មណ៍ទាំងនេះ អូសចេញទៅ ដូច្នេះនាងទើបបង្គាប់ឲ្យគេនាំព្រាហ្មណ៍ទាំងនោះចេញ ។ ព្រាហ្មណ៍ទាំងនោះ មានសេចក្តីអៀនខ្មាស ហើយទៅកាន់រាជនិវេសន៍ ខឹងក្រោធនឹងនាងឧម្មាទន្តី ទើបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព នាងឧម្មាទន្តីនោះ ជាស្រីកាឡកណ្ណី មិនសមគួរនឹងព្រះអង្គទេ ។ ព្រះរាជាឮព្រាហ្មណ៍ទាំងនោះថា នាងឧម្មាទន្តី ជាស្រីកាឡកណ្ណីដូច្នេះទើបមិនបានបញ្ជាគេ ឲ្យទៅនាំនាងមក ។ នាងឧម្មាទន្តីស្តាប់ដំណឹងនោះហើយ ពោលថា ព្រះរាជាមិនទទួលយើងដោយសម្គាល់ថា បានឮមកថា យើងជាស្រីកាឡកណ្ណី ដែលឈ្មោះថា ស្រីកាឡកណ្ណី រមែង

មិនមានរូបដូចនេះឡើយ ។ នាងក៏គិតថា បើយ៉ាង នោះ ពេលយើងបានជួបព្រះរាជា នឹងដឹងគ្នាម្តង ដូច្នេះទើបចង់អាឃាតនឹងព្រះរាជានោះ ។ លំដាប់ នោះ តិរិដិវច្ឆសេដ្ឋីជាបិតាប្រគល់នាងឧម្មាទន្តី ឲ្យទៅ អភិបារកៈ នាងជាទីស្រឡាញ់ពេញចិត្ត របស់អភិបារ-កៈ នោះ ។

សួរថា នាងមានរូបស្អាតយ៉ាងនេះ ដោយវិបាក កម្មអ្វី ?

ឆ្លើយថា នាងមានរូបស្អាតយ៉ាងនេះ ដោយ វិបាកការឲ្យសំពត់ក្រហម ។

បានឮមកថា ក្នុងអតីតកាល នាងកើតក្នុង ត្រកូលអ្នកក្រីក្រ ក្នុងនគរពារាណសី នាងឃើញស្ត្រី ទាំងឡាយ ដែលដល់ព្រមដោយបុណ្យ ស្លៀកសំពត់ ដែលជ្រលក់ដោយផ្កាដកគាំ លេងក្នុងថ្ងៃមហោស្រព នាងក៏ចង់ស្លៀកសំពត់បែបនោះ ដើរលេងដូចគេដែរ

ហើយប្រាប់មាតាបិតា កាលមាតាបិតាពោលថា នែកូន យើងជាមនុស្សក្រីក្រ យើងនឹងបានសំពត់បែបនោះអំពីណា ? នាងពោលថា បើយ៉ាងនោះ សូមលោកអនុញ្ញាតឲ្យខ្ញុំ ធ្វើការស៊ីឈ្នួលនឹងត្រកូលអ្នកមានមួយរូបគេដឹងគុណរបស់ខ្ញុំ ហើយនឹងឲ្យសំពត់នោះដល់ខ្ញុំ ដូច្នេះ កាលបានការអនុញ្ញាតពីមាតាបិតាហើយ នាងក៏ចូលទៅកាន់ត្រកូលមួយ ពោលថា យើងសូមធ្វើការស៊ីឈ្នួល ដោយសំពត់ជ្រលក់ដោយផ្កាជកគាំ ។ លំដាប់នោះ ពួកត្រកូលអ្នកមានពោលនឹងនាងថា កាលនាងធ្វើអស់ ៣ ឆ្នាំ យើងដឹងគុណនាង ហើយនឹងឲ្យ ។ នាងទទួលថា ល្អ រួចក៏ធ្វើការងារ ។ ពួកអ្នកត្រកូលដឹងគុណនាង កាលមិនទាន់គ្រប់ ៣ ឆ្នាំផង ក៏ឲ្យសំពត់ដទៃ មួយអន្ទើដោយសំពត់ ដែលជ្រលក់ដោយផ្កាជកគាំ ១ ដុំដល់នាង ដោយពោលថា នាងចូរទៅជាមួយនឹងសម្លាញ់របស់នាង មុជទឹករួច ស្លៀកសំពត់ចុះ ដូច្នេះ ទើបបញ្ជូននាងទៅ ។ នាងនាំសម្លាញ់

ទៅ ហើយដាក់សំពត់ក្រហមនៅលើច្រាំងស្ទឹង រួចនាំគ្នាមុជទឹក ។

ក្នុងខណៈនោះ សាវក ១ រូប របស់ព្រះពុទ្ធកស្សបទសពល ត្រូវចោរដណ្តើមចីវរ ហើយស្លៀកដណ្តប់មែកឈើ មកដល់កន្លែងនោះ ។ នាងឃើញសាវកនោះ គិតថា លោកម្ចាស់ដ៏ចម្រើននេះត្រូវចោរដណ្តើមចីវរ សំពត់ស្លៀកនេះជារបស់កម្រកើតឡើងដល់យើង ព្រោះភាពជាអ្នកមិនឲ្យទានក្នុងកាលមុន ដូច្នេះយើងនឹងហែកសំពត់ជាពីរចំណែក ហើយថ្វាយមួយចំណែក ដល់លោកម្ចាស់ គិតយ៉ាងនេះហើយនាងឡើងពីទឹកមក ស្លៀកសំពត់របស់ខ្លួន រួចពោលថា ឈប់សិន លោកម្ចាស់ ហើយថ្វាយបង្គំព្រះថេរៈ ហែកសំពត់ក្រហម ត្រង់កណ្តាល រួចប្រគេនមួយចំណែកដល់ព្រះថេរៈនោះ ។ ព្រះថេរៈចូលទៅក្នុងទីបិទបាំងមួយ បោះចោលមែកឈើ ស្លៀកជាយម្ខាង ដណ្តប់ជាយម្ខាង រួចចេញមក ។ គ្រានោះ ដោយរស្មីសំពត់

សរីរៈទាំងមូល របស់ព្រះថេរៈ ទៅជាមានពន្លឺតែមួយហាក់ដូចជាព្រះអាទិត្យទើបនឹងរះ ។ នាងបានឃើញព្រះថេរៈហើយ គិតថា ដំបូង លោកម្ចាស់របស់យើងមិនស្អាតទេ ឥឡូវនេះ លោករុងរឿងបីដូចជាព្រះអាទិត្យអរុណោទ័យ យើងនឹងថ្វាយសូម្បីចំណែកនេះដល់លោកទៀត ដូច្នេះទើបថ្វាយ សូម្បីចំណែកទី ២ ហើយ តាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់កាលត្រាច់ទៅកាន់ភពនិងភព គប្បីជាអ្នកទ្រទ្រង់រូបដ៏ឧត្តម បើបុរសណាឃើញ ខ្ញុំម្ចាស់ហើយ កុំឲ្យអាចឋិតនៅដោយសភាព របស់ខ្លួនឡើយ ស្ត្រីដទៃ ដែលឈ្មោះថា មានរូបស្អាតក្រៃលែងជាងខ្ញុំសូមកុំឲ្យមានឡើយ ។ ចំណែកព្រះថេរៈ ធ្វើការអនុមោទនា រួចចៀសចេញទៅ ។ នាងកាលត្រាច់អន្ទោលវិលវល់ក្នុងទេវលោក ក្នុងកាលនោះ ក៏បានកើត ក្នុងអរិដ្ឋបុរនគរ ហើយបានជាស្ត្រីមានរូបស្អាតដ៏ក្រៃលែង ។

លំដាប់នោះ ក្នុងនគរ ពួករាជបុរសឃោសនាមហោស្រពខែកត្តិក ប្រជាជននាំរៀបចំនគរ ក្នុងថ្ងៃពេញបូណ៌មីខែកត្តិក ។ អភិបារក:កាលទៅកាន់ទីរក្សារបស់ខ្លួន បានប្រាប់ប្រពន្ធថា នែនាងឧម្មាទន្តីដ៏ចម្រើន វេលាយប់ខែកត្តិកក្នុងថ្ងៃនេះ នឹងមានមហោស្រព ព្រះរាជានឹងធ្វើប្រទក្សិណនគរ នឹងយាងមកដល់ទ្វារផ្ទះនេះជាដំបូង នាងកុំសម្តែងខ្លួនឲ្យព្រះរាជាឃើញឡើយ បើព្រះរាជាឃើញនាង ទ្រង់មិនអាចនឹងតាំងសតិបានឡើយ ។ នាងឧម្មាទន្តីទទួលថា បពិត្រស្វាមី អ្នកចូរទៅចុះ ខ្ញុំដឹងហើយ ដូច្នេះកាលអភិបារក:ទៅហើយ នាងបង្គាប់ទាសីថា កាលព្រះរាជាយាងមកដល់ទ្វារផ្ទះនេះ នាងចូរប្រាប់យើង ។

គ្រានោះ កាលព្រះសូរិយាអស្តង្គតហើយ ពេលព្រះចន្ទ្រពេញបូណ៌មី កំពុងរះឡើង នគរដែលគេតាក់តែង ហាក់ដូចជាទេវនគរ ភ្លឺព្រោងព្រាតសព្វទិស ព្រះរាជា ប្រដាប់តាក់តែង ដោយគ្រឿងអលង្ការ

ទាំងពួង យាងទៅដោយរថអាជានេយ្យដ៏ប្រសើរ មាន ពួកអាមាត្យចោមរោម ធ្វើប្រទក្សិណនគរ ដោយយស ដ៏ធំ ហើយយាងដល់ទ្វារផ្ទះអភិបារកៈ ជាដំបូង ។ ផ្ទះ អភិបារកៈនោះ ឡោមព័ទ្ធ ដោយកំពែង ពណ៌ដូច មនោសិលា មានប៉មទ្វារ ដែលតាក់តែង មាន សោភ័ណភាពស្អាត គួរជាទីជ្រះថ្លា ។ ខណៈនោះ ទាសីក៏បានប្រាប់នាងឧម្មាទន្តី ។ នាងឲ្យទាសីកាន់ស្មុគ ផ្កា នាងមកឈរនៅជិតបង្អួច ធ្វើអាការដូចជាកិន្នរី ហើយបោះផ្កាទៅលើព្រះរាជា ។ ព្រះរាជាក្រឡេក មើលនាងហើយ ក៏វង្វេងដោយការវង្វេង នៃកិលេស មិនអាចនឹងតាំងសតិបាន រហូតមិនអាចចាំ បានថា នេះជាផ្ទះអភិបារកៈ ពេលនោះ ទ្រង់ហៅនាយសារថី កាលនឹងសួរ ទើបត្រាស់ ២ គាថាថា

**និវេសនំ កស្ស នុទំ សុនន្ទ,**

**បាការេន បណ្ឌុមយេន គុត្តំ;**

កា ទិស្សតិ អគ្គិសិខាវ ទូរេ,
វេហាយសំ បព្ពតគ្គេវ អច្ចិ។

ហៃសុនន្ទៈ នេះជាទីលំនៅ របស់នរណាហ្ន៎ ដែលព័ទ្ធព័ទ្ធ ដោយកំពែង ធ្វើដោយឥដ្ឋពណ៌ក្រហម ស្រ្តីអ្វីប្រាកដដូចអណ្តាតភ្លើង ក្នុងទីឆ្ងាយ ឬដូចជាអណ្តាតភ្លើង ពួង៏អាកាសលើកំពូលភ្នំ ។

ធីតា នុយំ កស្ស សុនន្ទ ហោតិ,
សុណិសា នុយំ កស្ស អថោបិ ភរិយា;
អក្ខាហិ មេ វិប្បមិធេវ បុដ្ឋា,
អបារុតា យទិ វា អត្ថិ ភត្តា។

ម្នាលសុនន្ទៈ ស្រ្តីនេះ ជាធីតារបស់នរណាហ្ន៎ ស្រ្តីនេះជាកូនប្រសា របស់នរណាហ្ន៎ ឬជាភរិយារបស់នរណា ប្រសិនបើ (ស្រ្តីនេះ) មិនទាន់មានគេហ្មង់ហែង ក្តី មានភស្តាក្តី យើងសួរហើយ ចូរអ្នកប្រាប់យ៉ាងឆាប់ ក្នុងកាលឥឡូវនេះ កុំខាន ។

*នាយសារថី កាលនឹងទូលព្រះរាជា ទើបពោល ២ គាថាថា*

**អហញ្ហិ ជានាមិ ជនិន្ទ ឯតំ,**
**មត្យា ច បេត្យា ច អថោបិ អស្សា;**
**តវេវ សោ បុរិសោ ភូមិបាល,**
**រត្តិន្ទិវំ អប្បមត្តោ តវត្ថេ។**

*បពិត្រព្រះជនិន្ទៈ ខ្ញុំព្រះអង្គស្គាល់ស្ត្រីនុ៎ះ ដាក់លាក់ អំពីចំណែកខាងមាតាផង អំពីចំណែកខាងបិតាផង ទាំងស្វាមីរបស់ស្ត្រីនោះ ក៏ខ្ញុំព្រះអង្គស្គាល់ បពិត្រព្រះភូមិបាល ស្វាមីនោះ ជាបុរសរបស់ព្រះអង្គហ្នឹងឯង ជាអ្នកមិនប្រហែសធ្វេសក្នុងប្រយោជន៍ របស់ព្រះអង្គទាំងយប់ទាំងថ្ងៃ ។*

**ឥទ្ធា ច ផីតា ច សុវឌ្ឍិតា ច,**
**អមច្ចោ ច តេ អញ្ញតរោ ជនិន្ទ;**

**តស្សេសា ករិយាកិចារកស្ស,**
**ឧម្មាទន្តី ជាមដេយ្យេន រាជ។**

*បពិត្រព្រះជនិន្ទៈ ព្រះអង្គមានអាមាត្យម្នាក់ ជាអ្នកស្ទុកស្តម្ភមាំមួន ជុំជ្រើង បពិត្រព្រះរាជា ស្ត្រីនោះឈ្មោះនាងឧម្មាទន្តី ជាប្រពន្ធ របស់អាមាត្យ ឈ្មោះអភិបារកៈនោះឯង ។*

*ពាក្យថា* **ស្ត្រីនោះឈ្មោះនាងឧម្មាទន្តី** *សេចក្តីថា បុរសណាឃើញនាង នាងតែងញ៉ាំងបុរសនោះ ឲ្យវង្វេង គឺមិនឲ្យតាំងសតិបាន ព្រោះហេតុនោះ គេទើបហៅនាងថា ឧម្មាទន្តី ។*

*ព្រះរាជា ស្តាប់ពាក្យនោះហើយ កាលនឹងសរសើរឈ្មោះរបស់នាង ទើបត្រាស់គាថាបន្ទាប់ថា*

**អម្ភោ អម្ភោ ជាមមិទំ ភមិស្សា,**
**មត្យា ច បេត្យា ច កាតំ សុសាធុ;**

**តេន ហិ មយ្ហំ អវលោកយន្តី,**
**ឧម្មត្តកំ ឧម្មទន្តី អកាសិ។**

*វ៉ុយ វ៉ុយ ឈ្មោះនេះ ដែលមាតាបិតាបានឲ្យដល់នាងនេះ ត្រូវល្អណាស់ បានជាថា ដូច្នោះ ព្រោះនាងឧម្មាទន្តី កាលក្រឡេកមើលអញ ធ្វើអញឲ្យឆ្កួត ។*

នាងឧម្មាទន្តីដឹងភាព ដែលព្រះរាជា មានចិត្តកម្រើកហើយ ក៏បិទបង្អួច ចូលកាន់បន្ទប់ដ៏មានសិរីវិញ ។ ចំណែកព្រះរាជា ចាប់ពីពេលឃើញនាងហើយ មានព្រះហឫទ័យ មិនអាចនឹងធ្វើប្រទក្សិណនគរបានទៀតឡើយ ។ ព្រះរាជាហៅនាយសារថីមកថា នែសុនន្ទៈសម្លាញ់ អ្នកចូរត្រឡប់រថ មហោស្រពនេះមិនសមគួរដល់យើងទេ សមគួរ ដល់អភិបារកសេនាបតីសូម្បីតែរាជសម្បត្តិ ក៏សមគួរដល់អភិបារកៈដែរ ដូច្នេះទើបបញ្ជាឲ្យរថត្រឡប់ ស្តេចឡើងកាន់ប្រាសាទ ផ្ទំលើសិរីសយនៈ កាលទ្រង់រវើរវាយ ទើបត្រាស់ថា

យា បុណ្ណមាសេ មិគមន្ទលោចនា,
ឧបាវិសិ បុណ្ឌរីកត្តចង្គី;
ទ្វេ បុណ្ណមាយោ តទហូ អមញ្ញហំ,
ទិស្វាន បារាវតរត្តវាសិនឹ។

*ស្ត្រីណាមានភ្នែកស្រទន់ដូចភ្នែកម្រឹគ មានសរីរៈសម្បុរដូចផ្កាឈូកក្រហម អង្គុយអែប ( ក្បែរបង្អួច) ក្នុងរាត្រី ដែលមានព្រះចន្ទពេញវង់ អញបានឃើញស្ត្រីនោះ ដែលមានសម្លៀកបំពាក់ក្រហម ដូចជាជើងព្រាប ក៏ស្មានថាជាព្រះចន្ទពេញវង់ពីរ ។*

អឡារបម្ហេហិ សុភេហិ វគ្គុភិ,
បលោភយន្តី មំ យទា ឧទិក្ខតិ;
វិជម្ភមានា ហរតេវ មេ មនោ,
ជាតា វនេ កិម្បុរិសីវ បព្ពតេ។

(នាងឧម្មាទន្តី) ប្រលោមអញ ដោយអាការទ្រទេសទ្រទន់ល្អស្រស់ ជាប្រធាននៃការដ៏វិសេស ម៉ឹកម៉ក់ក្រឡេកមើលអញ ចិត្តរបស់អញក៏រវើរវាយ ដូចជាក្នុងកាលដែលកិន្នរញីកើត ក្នុងព្រៃភ្នំ (ហិមពាន្តធ្វើកិន្នរឈ្មោល ឲ្យមានចិត្តរវើរវាយ ដូច្នោះ) ។

តទា ហិ ព្រហតី សាមា,
អាមុត្តមណិកុណ្ឌលា;
ឯកច្ចវសនា នារី,
មិគី ភន្តាវុទិក្ខតិ។

ត្បិតក្នុងកាលនោះ នាងនារីមានសម្បុរលឿងពាក់កុណ្ឌលកែវមណី មានសម្លៀកបំពាក់ តែមួយក្រឡេកមើល (អញ) ដូចជាមេម្រឹគផ្អើល ។

កទាស្សុ មំ តម្ពនខា សុលោមា,
ពាហា មុទូ ចន្ទនសារលិត្តា;

វដ្ដង្គុលី សន្នតធីរកុត្តិយា,
នារី ឧបញ្ញិស្សតិ សីសតោ សុភា។

កាលណាហ្ន៎ នឹងបាននារី មានក្រចកក្រហមទុំ មានពោមល្អ មានដើមដៃទន់ភ្លន់ លាបស្រឡាបដោយខ្លឹមចន្ទន៍ មានម្រាមដៃមូល ប្រសប់ខាងធ្វើម៉្រឹកម៉្រក់ ល្អផុតបុងសក់ មកឱបអង្អែលអញ ។

កទាស្សុ មំ កញ្ចនជាលុរច្ឆទា,
ធីតា តិរីដិស្ស វិលគ្គមជ្ឈា;
មុទូហិ ពាហាហិ បលិស្សជិស្សតិ,
ព្រហាវនេ ជាតទុមំវ មាលុវា។

កាលណាហ្ន៎ អញនឹងបានធីតា របស់សេដ្ឋី ឈ្មោះតិរិដិ ដែលមានគ្រឿងប្រដាប់ទ្រូង ជាវិការនៃមាស មានដងខ្លួនរៀវ មកឱបរឹតអញដោយដើមដៃ

*ទាំងពីរដ៏ទន់ភ្លន់ ដូចជា ពួរជ្រៃដែលរួបរឹតដើមឈើដុះក្នុងព្រៃធំ ។*

កកាស្សុ លាខារសរត្តសុច្ឆវី,
ពិន្ទុត្ថនី បុណ្ឌរីកត្តចង្គី;
មុទុំ មុទេន ឧបឈាមយិស្សតិ,
សោណ្ឌោវ សោណ្ឌស្ស សុរាយ ថាលំ។

*កាលណាហ្ន៎ អញនឹងបាន (នារី) ដែលមានសម្បុរល្អស្រស់ ដូចជាទឹកល័ក្តក្រហម មានដោះក្បុំដូចជាពពុះទឹក មានសរីរៈសម្បុរ ដូចផ្កាឈូកក្រហម បង្អោនមុខមកប៉ះនឹងមុខ (អញ) ដូចជាអ្នកលេង (ដែលហុច) កែវសុរា ឲ្យដល់អ្នកលេងផងគ្នា ។*

យកាន្ទុសំ តំ តិដ្ឋន្តិំ, សព្ពកន្ទុំ មណោរមំ;
តតោ សកស្ស ចិត្តស្ស, ណាវពោធាមិ កញ្ចិនំ។

អញបានឃើញនារីនោះ មានខ្លួនសមរម្យសព្វអន្ទើ ជាតម្រេកនៃចិត្ត កំពុងឈរ ក្នុងកាលណា អញមិនបានជាឥស្សរៈ (លើចិត្តរបស់ខ្លួន) មិនស្គាល់នារីនោះ ថាជាអ្វីឡើយ ក្នុងកាលនោះ ។

ឧម្មាទន្តិមហំ ទដ្ឋា,
អាមុត្តមណិកុណ្ឌលំ;
ន សុបាមិ ទិវារត្តឹ,
សហស្សំវ បរាជិតោ។

អញបានឃើញ នាងឧម្មាទន្តី ដែលពាក់កុណ្ឌលជាវិការៈ នៃកែវមណី ក៏ដេកមិនលក់ទាំងថ្ងៃទាំងយប់ ដូចជាគេផ្ចាញ់អស់មួយពាន់ដង ។

សក្កោ ចេ មេ វរំ ទជ្ជា,
សោ ច លព្ភេថ មេ វរោ;

ឯកាវត្តំ ទិវត្តំ វា,
ករេយ្យំ អភិបារកោ;
ឧម្មាទន្ត្យា រមិត្វាន,
សិវិរាជា តតោ សិយំ។

*បើសក្កទេវរាជប្រទានពរដល់អញ សូមឲ្យអញបានពរនោះថា អភិបារកសេនាបតី សូមត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តី តែមួយយប់ពីរយប់ ប៉ុណ្ណោះចុះ តពីនោះទៅ សូមព្រះបាទសិវិរាជ (ត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តីវិញ) ។*

*លំដាប់នោះ ពួកអាមាត្យប្រាប់រឿងនោះ ដល់អភិបារកៈថា បពិត្រលោកម្ចាស់ ព្រះរាជាកាលប្រទក្សិណនគរ បានទៅដល់ទ្វារផ្ទះ របស់លោកហើយយាងត្រឡប់ ទ្រង់ឡើងកាន់ប្រាសាទ ។ អភិបារកៈទៅផ្ទះរបស់ខ្លួន ហៅនាងឧម្មាទន្តីមកសួរថា នៃនាង នាងមានបានសម្តែងខ្លួនឲ្យព្រះរាជាឃើញឬ ?*

នាងឧម្មាទន្តីពោលថា បពិត្រស្វាមី មានបុរសម្នាក់ មានពោះធំ មានចង្កូមធំ ឋិតនៅលើរថ មក ខ្ញុំមិនដឹងថា បុរសនោះជាព្រះរាជា ឬមិនមែនជាព្រះរាជាទេ តែកាលគេពោលថា បុរសឯកជាធំ ដូច្នេះខ្ញុំឋិតនៅជិតបង្អួច ក៏បោះផ្កាទៅ ក្នុងពេលនោះ បុរសនោះក៏វិលត្រឡប់ទៅវិញ ។ អភិបារកៈស្តាប់ពាក្យនោះហើយ ពោលថា នាងឲ្យយើងវិនាសហើយ ។

ថ្ងៃស្អែក ក្នុងអំពីព្រឹក អភិបារកៈឡើងទៅកាន់រាជនិវេសន៍ ឋិតនៅជិតទ្វារបន្ទប់ដ៏មានសិរី ស្តាប់ការនិយាយរវើរវាយ ដោយអាស្រ័យនាងឧម្មាទន្តី របស់ព្រះរាជា ហើយគិតថា ព្រះរាជានេះកើតចិត្តប្រតិព័ទ្ធនឹងនាងឧម្មាទន្តី កាលនឹងមិនបាននាង ព្រះអង្គនឹងសោយទិវង្គត យើងត្រូវញុំាងទោសរបស់ព្រះរាជា និងរបស់យើងឲ្យរួចផុត ហើយយើងគួរថ្វាយជីវិត ដល់ព្រះរាជានេះ ដូច្នេះទើបទៅកាន់និវេសន៍ របស់ខ្លួនហៅឧបដ្ឋាកដ៏ជិតស្និទ្ធម្នាក់មកប្រាប់ថា នៃអ្នក ក្នុងទីឯ

ណោះ មានដើមឈើប្រហោងដែលជាចេតិយ អ្នកកុំឲ្យអ្នកណាដឹងឡើយ កាលព្រះអាទិត្តអស្តង្គតទៅ អ្នកចូរទៅទីនោះ អង្គុយខាងក្នុងដើមឈើ កាលយើងទៅធ្វើពលិកម្មនៅទីនោះ ដល់កន្ទែងនោះ ហើយមនស្ការទេវតា សូមអង្វរថា បពិត្រទេវរាជជាម្ចាស់ កាលមហោស្រពមានក្នុងនគរ ព្រះរាជារបស់ពួកខ្ញុំ ទ្រង់មិនមកក្រសាលឡើយ ព្រះអង្គចូលក្នុងបន្ទប់ដ៏មានសិរី ផ្ទំរវើររវាយ ពួកខ្ញុំមិនដឹងហេតុនោះទេ ព្រះរាជាមានឧបការៈច្រើនដល់ទេវតា តែងលះបង់ទ្រព្យ ១០០០ រាល់ៗ ឆ្នាំ ដើម្បីធ្វើពលិកម្ម សូមលោកមេត្តាប្រាប់ថា ព្រះរាជានេះរវើររវាយ ដោយអាស្រ័យអ្វី សូមលោកឲ្យជីវិតដល់ព្រះរាជារបស់ពួកខ្ញុំផង ដូច្នេះ ក្នុងពេលនោះ អ្នកធ្វើសំឡេងឲ្យប្រែប្រួល ពោលឡើងថា នៃសេនាបតី ព្រះរាជារបស់លោក មិនមានអាពាធទេ ព្រះរាជានោះមានចិត្តប្រតិព័ទ្ធនឹងនាងឧម្មាទន្តី ដែលជាភរិយារបស់លោក ប្រសិនបើបាននាង ព្រះអង្គនឹងមានជីវិត

បើមិនបានទេ ទ្រង់នឹងសោយទិវង្គត បើលោកប្រាថ្នា ឲ្យជីវិតដល់ទ្រង់ ចូរថ្វាយនាងឧម្មាទន្តី ដល់ព្រះអង្គចុះ ដូច្នេះហើយ អភិបារកៈក៏ឲ្យឧបដ្ឋាកចង់ចាំពាក្យនោះ យ៉ាងនេះហើយ ទើបបញ្ជូនទៅ ។

ឧបដ្ឋាកនោះ ទៅហើយ អង្គុយក្នុងដើមឈើ ស្អែកឡើង កាលសេនាបតី ដែលមានពួកអាមាត្យ ជាបរិវារទៅកាន់កន្លែងនោះ ពោលសូមអង្វរហើយ គេក៏បានពោលយ៉ាងនោះ (តាមគម្រោងគ្រប់ប្រការ) ។ សេនាបតីពោលថា ល្អ ហើយថ្វាយបង្គំទេវតា និងឲ្យពួកអាមាត្យទទួលដឹងរួចហើយ ទើបចូលទៅកាន់នគរ ឡើងកាន់រាជនិវេសន៍ ទៅទោះទ្វារបន្ទប់ ។ ព្រះរាជាខំតាំងសតិ ហើយត្រាស់ថា អ្នកជានរណា ។ អភិបារកៈទូលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ អភិបារកៈ។ ពេលនោះ ព្រះរាជាបើកទ្វារ ។ សេនាបតីចូលទៅហើយ ថ្វាយបង្គំព្រះរាជា រួចពោលគាថាថា

ភូតានិ មេ ភូតបតី នមស្សតោ,
អាគម្ម យក្ខោ ឥទមេតទព្រវិ;
រញ្ញោ មនោ ឧម្មទន្ត្យា និវិដ្ឋោ,
ទទាមិ តេ តំ បរិចារយស្សុ។

បពិត្រព្រះអង្គ ជាម្ចាស់នៃជន កាលដែលទូលព្រះបង្គំជាខ្ញុំ សំពះទេវតាទាំងឡាយ មានទេវតា (មួយអង្គ) មកពោលពាក្យដូច្នេះថា ព្រះទ័យរបស់ព្រះរាជា ជាប់ជំពាក់នឹងនាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គ សូមព្រះអង្គឲ្យនាងឧម្មាទន្តីនោះបម្រើចុះ ។

ពាក្យថា **កាលដែលទូលព្រះបង្គំជាខ្ញុំ សំពះទេវតាទាំងឡាយ** សេចក្តីថា កាលដែលទូលព្រះបង្គំជាខ្ញុំធ្វើពលិកម្ម ដើម្បីដឹងហេតុ នៃការរវើរវាយ របស់ព្រះអង្គ បាននមស្ការទេវតា ។ ពាក្យថា **សូមព្រះអង្គឲ្យនាង**

**ឧម្មាទន្តីនោះ** សេចក្តីថា ទូលព្រះបង្គំនឹងធ្វើនាងឧម្មាទន្តីនោះឲ្យជាបរិចារិកា របស់ព្រះអង្គ ហើយថ្វាយ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរអភិបារកៈ ថា នៃអភិបារកៈសម្លាញ់ សូម្បីពួកយក្ស ក៏ដឹងភាពរវើរវាយ ព្រោះមានចិត្តប្រតិព័ទ្ធនាងឧម្មាទន្តី របស់យើងឬ ? សេនាបតីទូលថា ពិតមែនហើយព្រះអង្គ ។ ព្រះរាជានោះគិតថា បានឮថា ភាពអាក្រក់របស់យើង គឺសត្វលោកទាំងអស់ បានដឹងហើយ ដូច្នេះទ្រង់តាំងនៅក្នុងលជ្ជិធម៌ (ធម៌ធ្វើឲ្យកើតសេចក្តីអៀនខ្មាស បាប) ត្រាស់គាថាបន្ទាប់ថា

**បុញ្ញា ច ធំសេ អមរោ ន ចម្ហិ,**
**ជនោ ច មេ បាបមិទញ្ច ជញ្ញា;**
**ភុសោ ច ត្យស្ស មនសោ វិឃាតោ,**
**ទត្វា បិយំ ឧម្មទន្តឹ អទដ្ឋា។**

**ខ្ញុំគប្បីឃ្លាត ចាកបុណ្យផង ខ្ញុំមិនមែនជាមិនស្លាប់ផង អ្នកផងដឹងនូវអំពើអាក្រក់ របស់ខ្ញុំនេះផង សេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នក យ៉ាងខ្លាំងព្រោះអ្នកឲ្យ (នាងឧម្មាទន្តី) ជាទីស្រឡាញ់ហើយមិនបានឃើញទៀតផង ។**

*ពាក្យថា **ខ្ញុំគប្បីឃ្លាតចាកបុណ្យផង** សេចក្តីថានៃអភិបារកៈសម្លាញ់ កាលយើងបម្រើដោយអំណាចកិលេស មួយអន្លើដោយនាងឧម្មាទន្តីនោះ គប្បីឃ្លាតចាកបុណ្យផង យើងក៏មិនបានជាទេវតា ដោយត្រឹមតែការបម្រើ មួយអន្លើ ដោយនាងឧម្មាទន្តីនោះផងស្តេចជាធំទាំងឡាយ គប្បីដឹងភាពលាមកនេះ របស់យើងហើយ គប្បីតិះដៀលថា ព្រះរាជាធ្វើអំពើមិនសមគួរ ដូច្នេះផង អ្នកកាលឲ្យករិយាដល់យើងហើយ*

ខាងក្រោយមក មិនបានឃើញកិរិយា ជាទីស្រឡាញ់ សេចក្ដីបង្អៀតបង្អល់ចិត្តនឹងមានដល់អ្នកផង ។

ពាក្យដ៏សេស ជាគាថាឆ្លើយឆ្លង របស់ព្រះរាជា និង អភិបារកៈទាំងពីរនោះ ៖

(អភិបារកៈពោលថា)

ជនិន្ទ ជានាសិ តយា មយា វា,
សព្ពាបិ កម្មស្ស កតស្ស ជញ្ញា;
យំ តេ មយា ឧម្មទន្តី បទិន្នា,
ករោហិ រាជា វនថំ សជាហិ។

បពិត្រព្រះជនិន្ទៈ លើកលែងតែព្រះអង្គ និង ទូលព្រះបង្គំជាខ្ញុំចេញ អ្នកទាំងពួង មិនគប្បីដឹងនូវអំពើ ដែលទូលព្រះបង្គំជាខ្ញុំ ថ្វាយនាងឧម្មាទន្តី ដល់ព្រះអង្គ ទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យ

ខ្ញុំផ្កាចុះ (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យ ហើយ សូមលះបង់ចុះ) ។

(ព្រះបាទសិវិរាជត្រាស់ថា)

យោ បាបកំ កម្មករំ មនុស្សោ,
សោ មញ្ញតិ មាយិទ មញ្ញឹសុ អញ្ញេ;
បស្សន្តិ ភូតានិ ករោន្តមេតំ,
យុត្តា ច យេ ហោន្តិ នរា បថព្យា។

មនុស្សណា ធ្វើអំពើអាក្រក់ មនុស្សនោះ តែងសម្គាល់ថា ជនទាំងឡាយដទៃ ពុំដឹងនូវអំពើអញនេះឡើយ តែពួកភូត និងពួកនរជនដែលប្រកប (ដោយឫទ្ធិ) លើផែនដី រមែងឃើញបុគ្គលដែលធ្វើបាបកម្មនុ៎ះ ។

អញ្ញោ នុ តេ កោចិ នរោ បថព្យា,
សទ្ធេយ្យ លោកស្មិ ន មេ បិយាតិ;

កុសោ ច ត្យស្ស មនុសោ វិឃាតោ,
នត្វា បិយំ ឧម្មទន្តិំ អនដ្ឋា។

ជនដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿចិត្តអ្នកថា នាង (ឧម្មាទន្តី) មិនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាង ឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀត ។

(អភិបារក:ពោលថា)

អទ្ធា បិយា មយ្ហ ជនិន្ទ ឯសា,
ន សា មមំ អប្បិយា ភូមិបាល;
គច្ចេវ តុំ ឧម្មទន្តិំ ភទន្តេ,
សីហោវ សេលស្ស គុហំ ឧបេតិ។

បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះ

ភូមិបាល នាងនោះ មិនមែនមិនជាទីស្រឡាញ់ របស់ទូលព្រះបង្គំជាខ្ញុំទេ សូមសេចក្ដីចម្រើន ចូរមានដល់ព្រះអង្គ សូមព្រះអង្គយាងទៅកាន់សម្នាក់នាងឧម្មាទន្ដីកុំខាន ដូចជាសីហៈឈ្មោលចូលទៅកាន់គុហាកែវមណី (ជាលំនៅរបស់សីហៈញី) ដូច្នោះ ។

(ព្រះរាជាត្រាស់ថា)

ន បីឡិតា អត្តទុខេន ធីរា,
សុខប្ផលំ កម្ម បរិច្ចជន្តិ;
សម្មោហិតា វាបិ សុខេន មត្តា,
ន បាបកម្មញ្ច សមាចរន្តិ។

អ្នកប្រាជ្ញទាំងឡាយ (បើទុកជា) ត្រូវសេចក្ដីទុក្ខក្នុងខ្លួនបៀតបៀនហើយ ក៏មិនលះបង់ នូវអំពើដែលមានផលជាសុខឡើយ ឬទោះបើវង្វេង ជ្រុលជ្រប់

ក្តី ស្រវឹងដោយសេចក្តីសុខក្តី ក៏គង់មិនប្រព្រឹត្តធ្វើ
បាបកម្មទេ ។

(អភិបារកៈពោលថា)

តុវញ្ហិ មាតា ច បិតា ច មយ្ហំ,
កត្តា បតី ពោសកោ ទេវតា ច;
ទាសោ អហំ តុយ្ហ សបុត្តទារោ,
យថាសុខំ សាមិ ករោហិ កាមំ។

ព្រះអង្គដូចជាមាតាបិតា ជាអ្នកចិញ្ចឹម ជាម្ចាស់ ជាអ្នកបីបាច់រក្សា ទាំងជាទេវតារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះបាទសិរិ ខ្ញុំព្រះអង្គ ព្រមទាំងកូនប្រពន្ធជា ទាសៈរបស់ព្រះអង្គ សូមទ្រង់ធ្វើសេចក្តីប្រាថ្នា តាមសប្បាយចុះ ។

(ព្រះរាជាត្រាស់ថា)

យោ`ឥស្បុរោម្ហីតិ ករោតិ ចាបំ,
កត្វា ច សោ ឆុត្តសតេ បរេសំ;
ន តេន សោ ជីវតិ ទីឃមាយុ,
ទេវាបិ ចាបេន សមេក្ខរេ នំ។

*បុគ្គលណាអាងថា អាត្មាអញជាធំដូច្នេះហើយ ធ្វើនូវអំពើអាក្រក់ បុគ្គលនោះលុះបានធ្វើរួចហើយ ក៏មិនរអែងនឹងពួកជនដទៃ ព្រោះអំពើនោះ បុគ្គលនោះ មិនរស់នៅអស់កាលជាអង្វែង ទាំងពួកទេវតា ក៏តែងរំពៃមើលបុគ្គលនោះ ដោយអំពើអាក្រក់ ។*

*(អភិបារកៈពោលថា)*

អញ្ញាតកំ សាមិកេហិ បទិន្នំ,
ធម្មេ ឋិតា យេ បដិច្ឆន្តិ ទានំ;
បដិច្ឆកា ទាយកា ចាបិ តត្ថ,
សុខប្ចូលញ្ញោរ ការេន្តិ កម្មំ។

បុគ្គលទាំងឡាយណា តាំងនៅក្នុងធម៌ ទទួលយកនូវទាន ដែលគេមិនស្គាល់ ដែលម្ចាស់ទាំងឡាយប្រគល់ឲ្យហើយ បុគ្គលជាអ្នកទទួលទាំងឡាយ (នោះ) ផង អ្នកឲ្យទាំងឡាយផង ឈ្មោះថាធ្វើនូវអំពើមានផលជាសុខក្នុងហេតុនោះ ។

(ព្រះរាជាត្រាស់ថា)

អញ្ញោ នុ តេ កោចិ នរោ បថព្យា,<br>
សទ្ទេយ្យ លោកស្មិ ន មេ បិយាតិ,<br>
ភុសោ ច ត្យស្ស មនសោ វិឃាតោ,<br>
ទត្វា បិយំ ឧម្មទន្តិំ អទដ្ឋា។

បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្តគប្បីមានដល់

អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ។

(អភិបារកៈពោលថា)

អទ្ធា បិយា មយ្ហ ជនិន្ទ ឯសា,
ន សា មមំ អប្បិយា ភូមិបាល;
យំ តេ មយា ឧម្មទន្តី បទិន្នា,
ភុសេហិ រាជា វនថំ សជាហិ។

បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំ ដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់ របស់ទូលព្រះបង្គំជាខ្ញុំទេ នាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំបានថ្វាយហើយ ចំពោះព្រះអង្គ ដោយហេតុណា បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្លាំងក្លាចុះ

*(បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យ) សូមលះបង់ចុះ ។*

*(ព្រះរាជាត្រាស់ថា)*

យោ អត្តទុក្ខេន បរស្ស ទុក្ខំ,
សុខេន វា អត្តសុខំ ទហាតិ;
យថេវិទំ មយ្ហ តថា បរេសំ,
យោ ឯវំ ជានាតិ ស វេទិ ធម្មំ។

*បុគ្គលណាឲ្យទុក្ខដល់ជនដទៃ ដោយទុក្ខរបស់ខ្លួន ឬ ដណ្តើមសុខ ដើម្បីខ្លួន អំពីសុខ (របស់ជនដទៃ) (បុគ្គលនោះ ឈ្មោះថា មិនស្គាល់ធម៌) លុះតែបុគ្គលណាដឹងច្បាស់យ៉ាងនេះថា សុខទុក្ខ របស់អញនេះយ៉ាងណា សុខទុក្ខរបស់ជនដទៃ ក៏យ៉ាងនោះដែរ បុគ្គលនោះទើបឈ្មោះថា អ្នកដឹងធម៌ ។*

អញ្ញោ នុ តេ កោចិ នរោ បថព្យា,
សទ្ធេយ្យ លោកស្មិំ ន មេ បិយាតិ;
កុសោ ច ត្យស្ស មនសោ វិឃាតោ,
ទត្វា បិយំ ឧម្មទន្តិំ អនដ្ឋា។

*បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ។*

( *អភិបារកៈពោលថា* )

ជនិន្ទ ជាណាសិ បិយា មមេសា,
ន សា មមំ អប្បិយា ភូមិពាល;
បិយេន តេ ទម្មិ បិយំ ជនិន្ទ,
បិយទាយិនោ ទេវ បិយំ លភន្តិ។

បពិត្រព្រះជនិន្ទៈ ព្រះអង្គគង់ជ្រាបថា នាងឧម្មាទន្តីនុ៎ះជាទីស្រឡាញ់ របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះភូមិបាល នាងនោះ មិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ បពិត្រព្រះជនិន្ទៈ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តីជាទីស្រឡាញ់ ចំពោះព្រះអង្គ ដោយចិត្តជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព បុគ្គលអ្នកឲ្យនូវវត្ថុ ជាទីស្រឡាញ់ទាំងឡាយ រមែងបាននូវវត្ថុជាទីស្រឡាញ់វិញ។

(ព្រះរាជាត្រាស់ថា)

សោ នូនាហំ វធិស្សាមិ,
អត្តានំ កាមហេតុកំ,
ន ហិ ធម្មំ អធម្មេន,
អហំ វធិតុមុស្សហេ។

អញនោះមុខជានឹងសម្លាប់ខ្លួន ព្រោះមានកាមជាហេតុ ដោយពិត អញនឹងមិនអាច ដើម្បីសម្លាប់នូវធម៌ដោយអធម៌ឡើយ ។

(អភិបារកៈពោលថា)

សចេ តុវំ មយ្ហ សតឹ ជនិន្ទ,
ន កាមយាសិ នរវីរ សេដ្ឋ;
ចជាមិ នំ សព្ពជនស្ស សិព្យា,
មយា បមុត្តំ តតោ អវ្ហយសិ នំ។

បពិត្រព្រះជនិន្ទៈ ទ្រង់មានព្យាយាម ក្នុងពួកជនដ៏ប្រសើរ បើព្រះអង្គមិនសព្វព្រះរាជហឫទ័យនឹងនាងឧម្មាទន្តី ដែលជារបស់ទូលព្រះបង្គំជាខ្ញុំទេ ទូលព្រះបង្គំជាខ្ញុំ នឹងលះបង់ នាងនាកណ្តាលជនទាំងពួង តពីនោះ

ទៅ ព្រះអង្គគប្បីនាំយក នាងឧម្មាទន្តីនោះ ដែលទូលព្រះបង្គំជាខ្ញុំលះបង់ហើយ ។

(ព្រះរាជាត្រាស់ថា)

អទូសិយំ ចេ អភិចារក ត្វំ,
ចជាសិ កត្តេ អហិតាយ ត្យស្ស;
មហា ច តេ ឧបវាទោបិ អស្ស,
ន ចាបិ ត្យស្ស នគរម្ហិ បក្ខោ។

នែអភិបារកៈ បើអ្នកលះបង់ (នាងឧម្មាទន្តី) ដែលមិនមានទោស នៃអ្នកធ្វើ (ប្រយោជន៍ដល់ខ្ញុំ) ការលះបង់នោះ គប្បីមិនជាប្រយោជន៍ ដល់អ្នកផង ពាក្យតំណិះ ដំណៀលយ៉ាងច្រើន គប្បីមានដល់អ្នកផង បក្សពួករបស់អ្នកក្នុងនគរ មិនគប្បីមានផង ។

(អភិបារកៈពោលថា)

អហំ សហិស្សំ ឧបវាទមេតំ,
និន្ទំ បសំសំ គរហញ្ច សព្វំ;
មមេតមាគច្ឆតុ ភូមិបាល,
យថាសុខំ សិវិ ករោហិ កាមំ។

បពិត្រព្រះភូមិបាល ទូលព្រះបង្គំជាខ្ញុំ នឹងអត់ទ្រាំនូវពាក្យ តំណិះដំណៀលនុ៎ះផង នូវនិន្ទាផង នូវសេចក្ដីសរសើរផង និងការពោលទោសគ្រប់យ៉ាងថា ហេតុទាំងនុ៎ះ ចូរមកដល់ទូលព្រះបង្គំជាខ្ញុំចុះ បពិត្រព្រះបាទសិវិ សូមទ្រង់ធ្វើនូវសេចក្ដីប្រាថ្នា តាមសប្បាយចុះ ។

យោ វេ និន្ទំ ច បចប្បសំសំ,
អាទិយតិ គរហំ ដោបិ បូជំ;
សិរី ច លក្ខី ច អបេតិ តម្ហា,
អាថោ សុវុដ្ឋីវ យថា ថលម្ហា។

បុគ្គលណា មិនអើពើនឹងនិន្ទា មិនអើពើនឹងសេចក្តីសរសើរ មិនអើពើនឹងពាក្យពោលទោស មិនអើពើនឹងការបូជា សិរីក្តី បញ្ញាក្តី រមែងទៅប្រាសចាកបុគ្គលនោះ ដូចជាទឹក គឺទឹកភ្លៀងយ៉ាងស្រួល ដែលទៅប្រាសចាកទីទួលដូច្នោះ ។

យំ កិញ្ចិ ទុក្ខញ្ច សុខញ្ច ឯត្ថ,
ធម្មាតិសារញ្ច មនោវិឃាតំ;
ឧរសា អហំ បច្ចុត្តរិស្សាមិ សព្វំ,
បថវី យថា ថាវរានំ តសានំ។

ទូលព្រះបង្គំជាខ្ញុំ នឹងទទួលនូវសេចក្តីទុក្ខផង នូវសេចក្តីសុខផង នូវអំពើអាក្រក់ហួសផ្លូវធម៌ផង នូវសេចក្តីចង្អៀតចង្អល់ចិត្ត គ្រប់យ៉ាង តាមតែយ៉ាងណាក៏ដោយ អំពីដំណើរនេះ ដោយផ្ទាល់ទ្រូង ដូចជាផែនដី

(ដែលទទួលនូវវត្ថុណាមួយ) របស់ពួកជនអ្នកមាំមួន គឺព្រះអរហន្ត និងរបស់ពួកជនអ្នកតក់ស្លុត គឺបុថុជ្ជន ។

(ព្រះរាជាត្រាស់ថា)

ធម្មាតិសារញ្ច មនោវិយាតំ,
ទុក្ខញ្ច និច្ឆាមិ អហំ បរេសំ;
ឯកោឥមំ ហារយិស្សាមិ ភារំ,
ធម្មេ ឋិតោ កិញ្ចិ អហាបយន្តោ។

ខ្ញុំមិនប្រាថ្នាអំពើអាក្រក់ហួសផ្លូវធម៌ផង សេចក្តីទុក្ខជាគ្រឿងចង្អៀតចង្អល់ចិត្តផង ដល់ជនទាំងឡាយដទៃទេ ខ្ញុំតែម្នាក់ឯង ឋិតនៅក្នុងធម៌ មិនញ៉ាំងប្រយោជន៍បន្តិចបន្តួច ឲ្យសាបសូន្យទៅទេ ហើយនឹងធ្វងនូវភារៈ គឺសេចក្តីទុក្ខនេះ។

(អភិបារកៈពោលថា)

សគ្គបកំ បុញ្ញកម្មំ ជនិន្ទ,
មា មេ តុវំ អន្តរាយំ អកាសិ;
ទទាមិ តេ ឧម្មទន្តិំ បសន្នោ,
រាជាវ យញ្ញោ ធនំ ព្រាហ្មណានំ។

បពិត្រព្រះជនិន្ទៈ ព្រះអង្គកុំធ្វើនូវបុញ្ញកម្ម ជាគ្រឿងញ៉ាំងសត្វឲ្យកើត ក្នុងឋានសួគ៌ របស់ទូលព្រះបង្គំជាខ្ញុំ ឲ្យអន្តរាយឡើយ ទូលព្រះបង្គំជាខ្ញុំជ្រះថ្លា ថ្វាយនាងឧម្មាទន្តី ចំពោះព្រះអង្គ ដូចជា ព្រះរាជា (ដែលទ្រង់ព្រះរាជទាន) នូវទ្រព្យ ក្នុងការបូជា ដល់ពួកព្រាហ្មណ៍ ។

(ព្រះរាជាត្រាស់ថា)

អត្ថា តុវំ កាមេ ហិតេសិ មយ្ហំ,
សខា មមំ ឧម្មទន្តី តុវញ្ច;

និន្ទេយ្យុ ទេវា បិតរោ ច សព្វេ,
បាបញ្ច បស្សំ អភិសម្បរាយំ។

ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គល មានប្រយោជន៍ដល់ខ្ញុំ ដោយពិត នាងឧម្មាទន្តី និងអ្នកជាសម្លាញ់របស់ខ្ញុំ ពួកទេវតានិងទេវតាជាបិតា និងអ្នកទាំងអស់មុខជានិន្ទា ទាំងខ្ញុំក៏មុខជានឹងឃើញនូវបាបក្នុងអភិសម្បរាយភពពុំខាន ។

(អភិបារកៈពោលថា)

ន ហេតធម្មំ សិវិរាជ វជ្ជុំ,
សនេគមា ជានបទា ច សព្វេ;
យំ តេ មយា ឧម្មទន្តី បទិន្នា,
កុសេហិ រាជា វនថំ សហាហិ។

បពិត្រព្រះបាទសិវិ ពួកអ្នកនិគម និងពួកអ្នកជនបទទាំងអស់គ្នា មិនគប្បីពោលនូវអំពើ ដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយនាងឧម្មាទន្តី ចំពោះព្រះអង្គនុ៎ះថាជាធម៌ទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ (តណ្ហា) ឲ្យខ្ចាំងក្ងា (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យហើយ) សូមលះបង់ចុះ ។

(ព្រះរាជាត្រាស់ថា)

អទ្ធា តុវំ កត្តេ ហិតេសិ មយ្ហំ,
សខា មមំ ឧម្មទន្តី តុវញ្ច;
សតញ្ច ធម្មានិ សុកិត្តិតានិ,
សមុទ្ទវេលាវ ទុរច្ចយានិ។

ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គល មានប្រយោជន៍ ដល់ខ្ញុំដោយពិត នាងឧម្មាទន្តី និងអ្នកជា

សម្មាញ់របស់ខ្ញុំ ធម៌ទាំងឡាយ ដែលពួកសប្បុរសបាន សំដែងល្អហើយ ខ្ញុំប្រព្រឹត្តកន្លងបានដោយកម្រ ដូចជាសមុទ្រនិងច្រាំង ។

(អភិបារកៈពោលថា)

អាហុនេយ្យោ មេសិ ហិតានុកម្បី,
ធាតា វិធាតា ចសិ កាមបាលោ;
តយី ហុតា រាជ មហប្ផលា ហិ,
កាមេន មេ ឧម្មទន្តី បដិច្ឆ។

ព្រះអង្គជាអាហុនេយ្យបុគ្គល ជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកទ្រទ្រង់ ជាអ្នកចាត់ចែង (ឥស្សរិយសុខ) និងជាអ្នករក្សានូវសេចក្តីប្រាថ្នា របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះរាជា នាងឧម្មាទន្តីដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយព្រះអង្គនឹងមានផលច្រើន

សូមទ្រង់ទទួលយកនាង់ឧម្មាទន្តី តាមសេចក្តីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ ។

(ព្រះរាជាត្រាស់ថា)

អទ្ធា ហិ សព្ពំ អភិចារក ត្វំ,
ជម្មំ អចារី មម កត្តុបុត្ត;
អញ្ញោ នុ តេ កោ ឥធ សោត្ថិកត្តា,
ទ្វិបទោ នរោ អរុណេ ជីវលោកេ។

ម្នាលអភិបារកៈជាកូនរបស់សេនាបតី ជាអ្នកធ្វើនូវប្រយោជន៍ អ្នកមិនមែនជាបុគ្គលប្រព្រឹត្តនូវធម៌ទាំងអស់ ដល់ខ្ញុំដោយពិត ជនមានជើងពីរដទៃ តើរូបណាក្នុងជីវលោកនេះ ជាអ្នកធ្វើនូវសួស្តីដល់អ្នក ក្នុងពេលអរុណោទ័យ ។

(អភិបារកៈពោលថា)

តុវំ នុ សេដ្ឋោ ត្វមនុត្តរោសិ,
ត្វំ ធម្មគុត្តោ ធម្មវិទូ សុមេធោ;
សោ ធម្មគុត្តោ ចិរមេវ ជីវ,
ធម្មញ្ច មេ ទេសយ ធម្មបាល។

*ព្រះអង្គជាបុគ្គលប្រសើរផុត ព្រះអង្គជាបុគ្គលខ្ពង់ខ្ពស់ផុត ព្រះអង្គជាអ្នកដល់នូវធម៌ ជ្រាបច្បាស់នូវធម៌ មានព្រះប្រាជ្ញាប្រពៃ ទ្រង់ជាអ្នកគ្រប់គ្រងនូវធម៌ សូមទ្រង់មានព្រះជន្មាយុ អស់កាលដ៏អង្វែង បពិត្រព្រះធម្មបាល សូមទ្រង់សំដែងធម៌ ដល់ទូលព្រះបង្គំជាខ្ញុំ ។*

*( ព្រះរាជាត្រាស់ថា )*

តទិង្ឃ អកិចារកោ, សុណោហិ វចនំ មម;
ធម្មំ តេ ទេសយិស្សាមិ, សតំ អាសេវិតំ អហំ។

*បើដូច្នោះ ម្នាលអភិបារកៈ អ្នកចូរស្ដាប់ពាក្យខ្ញុំ ខ្ញុំនឹងសំដែងធម៌ ដែលពួកសប្បុរសធ្លាប់សេពដល់អ្នក ។*

សាធុ ធម្មរុចី រាជា, សាធុ បញ្ញាណវា នរោ;
សាធុ មិត្តានមទ្ទុព្ភោ, ចាបស្សាករណំ សុខំ។

*ព្រះរាជា ជាអ្នកគាប់ចិត្តដោយធម៌ ទើបល្អ ជនមានប្រាជ្ញា ទើបល្អ ការមិនប្រទូស្តមិត្ត ទើបល្អ កិរិយាមិនធ្វើបាប ទើបសុខ ។*

អក្កោធនស្ស វិជិតេ, ឋិតធម្មស្ស រាជិនោ;
សុខំ មនុស្សា អាសេថ, សីតច្ឆាយាយ សង្ឃរេ។

*មនុស្សទាំងឡាយ គប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ក្នុងម្លប់ដ៏ត្រជាក់ ក្នុងដែននៃស្ដេច ដែលមិនមានក្រោធ មានច្បាប់បិតថេរ ។*

ន ចាហមេតំ អភិរោចយាមិ,
កម្មំ អសមេក្ខកតំ អសាធុ;
យេ វាបិ ញត្វាន សយំ ករោន្តិ,
ឧបមា ឥមា មយ្ហំ តុវំ សុណោហិ។

ខ្ញុំមិនគាប់ចិត្តនឹងអំពើ ដែលមិនពិចារណាហើយធ្វើ ដែលធ្វើមិនប្រពៃនុ៎ះទេ ម្យ៉ាងទៀត ជនទាំងឡាយណាដឹងថា ( មិនប្រពៃ ) ហើយ មិនធ្វើដោយខ្លួនឯង (អំពើរបស់ជនទាំងឡាយនោះ ទើបខ្ញុំពេញចិត្ត ) អ្នកស្តាប់ពាក្យប្រៀបធៀបនេះ របស់ខ្ញុំចុះ ។

គវំ ចេ តរមានានំ, ជិម្ហំ គច្ឆតិ បុង្គវោ;
សព្ពា តា ជិម្ហំ គច្ឆន្តិ, នេត្តេ ជិម្ហំ គតេ សតិ។

កាលគោទាំងឡាយកំពុងឆ្លងទៅ បើគោបាទៅវៀចផ្លូវ កាលបើគោអ្នកនាំផ្លូវទៅវៀចហើយ ពួកមេគោទាំងអស់នោះ ក៏ដើរវៀចដែរ ។

ឯវមេវ មនុស្សេសុ, យោ ហោតិ សេដ្ឋសម្មតោ;
សោ ចេ អធម្មំ ចរតិ, បគេវ ឥតរា បជា;
សព្ពំ រដ្ឋំ ទុខំ សេតិ, រាជា ចេ ហោតិ អធម្មិកោ។

*បណ្តាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះ ប្រព្រឹត្តនូវអធម៌ទៅហើយ នឹងចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់ តែងដេកជាទុក្ខ ។*

គវំ ចេ តរមានានំ, ឧជុំ គច្ឆតិ បុង្គវោ;
សព្ពា គាវី ឧជុំ យន្តិ, នេត្តេ ឧជុំ គតេ សតិ។

*កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោបាទៅត្រង់ កាលបើគោអ្នកនាំផ្លូវទៅត្រង់ហើយ ពួកមេគោទាំងអស់នោះ ក៏ដើរទៅត្រង់ ។*

ឯវមេវ មនុស្សេសុ, យោ ហោតិ សេដ្ឋសម្មតោ;

សោ សចេ ធម្មំ ចរតិ, បគេវ ឥតរា បជា;
សព្ពំ រដ្ឋំ សុខំ សេតិ, រាជា ចេ ហោតិ ធម្មិកោ។

*បណ្ដាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណា ដែលអ្នកផងសន្មតថា ប្រសើរផុត បើជននោះប្រព្រឹត្ត ធម៌ នឹងចាំបាច់ពោលទៅថ្វី ដល់ប្រជាជនក្រៅនេះ បើ ព្រះរាជាទ្រង់ប្រកបដោយធម៌ រាស្ត្រទាំងអស់ រមែង ដេកជាសុខ ។*

ន ចាចាហំ អធម្មេន, អមរត្តមភិបត្ថយេ;
ឥមំ វា បឋវឹ សព្ពំ, វិជេតុំ អភិចារកា។

*ម្នាលអភិបារកៈ ខ្ញុំមិនប្រាថ្នានូវភាព នៃខ្លួនជា ទេវតា ដោយអធម៌ទេ ម្យ៉ាងទៀត (ខ្ញុំមិនប្រាថ្នា) ដើម្បី ឈ្នះនូវផែនដីទាំងមូលនេះ (ដោយអធម៌ទេ) ។*

យញ្ចិ កិញ្ចិ មនុស្សេសុ, រតនំ ឥធ វិជ្ជតិ;
គាវោ ទាសោ ហិរញ្ញញ្ច, វត្ថិយំ ហរិចន្ទនំ។

ថ្វីបើ ក្នុងមនុស្សលោកនេះ មានរតនវត្ថុណាមួយ គឺគោទាំងឡាយ ទាសៈ ប្រាក់ សំពត់ និងខ្លឹមចន្ទន៍ក្រហម ដោយពិតដូច្នោះ ។

អស្សិត្តិយោ រតនំ មណិកញ្ច,
យញ្ចាបិ មេ ចន្ទិមសូរិយា អភិបាលយន្តិ;
ន តស្ស ហេតុ វិសមំ ចរេយ្យំ,
មជ្ឈេ សិវីនំ ឧសភោម្ហិ ជាតោ។

ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយនេះ រក្សាទុកនូវរតនៈណាមួយ គឺសេះនិងស្ត្រីទាំងឡាយ កែវមណី បុគ្គលមិនគួរប្រព្រឹត្តនូវធម៌មិនស្មើ ព្រោះហេតុនៃរតនវត្ថុនោះៗ ទេ យើងដូចជាគោឧសភៈ កើតក្នុងចំណោមនៃពួកជនអ្នកនៅក្នុងដែនសិវិ ។

នេតា ហិតា ឧគ្គតោ រដ្ឋបាលោ,
ធម្មំ សិវីនំ អបចាយមានោ;

**សោ ធម្មមេវានុវិចិន្តយន្តោ,**
**តស្មា សកេ ចិត្តវសេ ន វត្តោ។**

*ខ្ញុំនោះជាអ្នកដឹកនាំ ជាអ្នកស្វែងរកប្រយោជន៍ ល្បីល្បាញរក្សានូវដែន លំអុតលំឱនចំពោះប្រពៃណី (របស់ស្តេចជាន់មុន) នៃអ្នកសិរិវាស្រ្តទាំងឡាយ ជាអ្នកត្រិះរិះតែធម៌ ព្រោះហេតុនោះ ខ្ញុំមិនលុះក្នុងអំណាចនៃចិត្តរបស់ខ្លួនទេ ។*

*(អភិបារកៈពោលថា)*

**អទ្ធា តុវំ មហារាជ, និច្ចំ អព្យសនំ សិវំ;**
**ការិស្សសិ ចិរំ រជ្ជំ, បញ្ញា ហិ តវ តាទិសី។**

*បពិត្រមហារាជ ព្រះអង្គនឹងសោយរាជសម្បត្តិទៀងទាត់ មិនវិនាស ក្សេមក្សាន្ត បានយូរយារ ដោយពិត ត្បិតប្រាជ្ញា របស់ព្រះអង្គប្រាកដដូច្នោះ ។*

ឯតំ តេ អនុមោទាម, យំ ធម្មំ នប្បមជ្ជសិ;
ធម្មំ បមជ្ជ ខត្តិយោ, រដ្ឋា ចវតិ ឥស្សរោ។

ព្រះអង្គមិនប្រមាទចំពោះធម៌ណា ទូលព្រះបង្គំជាខ្ញុំសូមអនុមោទនាចំពោះធម៌នុ៎ះរបស់ព្រះអង្គ ក្សត្រជាឥស្សរៈប្រមាទ ចំពោះធម៌ហើយ រមែងឃ្លាតចាកដែន ។

ធម្មំ ចរ មហារាជ, មាតាបិតូសុ ខត្តិយ;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងមាតាបិតាទាំងឡាយ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, បុត្តទារេសុ ខត្តិយ;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះរាជបុត្តនិងអគ្គមហេសី បពិត្រព្រះរាជា ព្រះអង្គ

ប្រព្រឹត្តធម៌ ក្នុងមនុស្សលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, មិត្តាមច្ចេសុ ខត្តិយ;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកមិត្តនិងអាមាត្យ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, វាហនេសុ ពលេសុ ច;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកវាហនៈផង ក្នុងពួកពលផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, គាមេសុ និគមេសុ ច;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកស្រុកផង ក្នុងពួកអ្នកនិគមផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, រដ្ឋេសុ ជនបទេសុ ច;
តត្ថ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកដែនផង ក្នុងពួកអ្នកជនបទផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, សមណព្រាហ្មណេសុ ច;
តត្ថ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងសមណៈផង ក្នុងពួកព្រាហ្មណ៍ផង បពិត្រព្រះរាជា

ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, មិគបក្ខីសុ ខត្តិយ;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកម្រឹគនិងបក្សី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, ធម្មោ ចិណ្ណោ សុខាវហោ;
ឥធ ធម្មំ ចរិត្វាន, រាជ សគ្គំ គមិស្សសិ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ (ត្បិត) ធម៌ ដែលគេសន្សំហើយ តែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ, សឥន្ទា ទេវា សព្រហ្មកា;

## សុចិណ្ណោ ធម៉ំ បត្តា, មា ធម្មំ រាជ ចាមនោ។

បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ (ត្បិត) ព្រះឥន្ទ្រទាំងឡាយ ទេវតាទាំងឡាយ ព្រមទាំងព្រហ្ម បានដល់នូវអត្តភាពជាទិព្វ ដោយសារធម៌ ដែលគេបាន សន្សំទុកល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រមាទ ចំពោះធម៌ឡើយ ។

*អភិបារកៈស្តាប់ធម្មកថា របស់ព្រះមហាសត្វ យ៉ាងនេះហើយ កាលធ្វើសេចក្តីសរសើរ ទើបពោល ថា* ***ព្រះអង្គនឹងសោយរាជសម្បត្តិទៀងទាត់*** *ដូច្នេះជា ដើម ។ ពាក្យថា* ***ព្រះអង្គមិនប្រមាទចំពោះធម៌ណា*** *សេចក្តីថា ព្រះអង្គមិនប្រមាទក្នុងធម៌ ដែលព្រះអង្គ បានសម្តែងមកហើយ ទ្រង់ចូរប្រព្រឹត្ត ក្នុងធម៌នោះ ប៉ុណ្ណោះ ។ ពាក្យថា* ***ក្សត្រជាឥស្សរៈប្រមាទចំពោះធម៌ ហើយ*** *សេចក្តីថា ប្រមាទចំពោះធម៌ហើយ នឹងលុះ*

ដោយអំណាចអគតិ ។ សេនាបតីនោះធ្វើការសរសើរព្រះរាជាយ៉ាងនេះហើយ កាលនឹងឲ្យព្រះរាជាប្រកបដោយធម្មចរិយា ទើបពោលឱវាទគាថា (គាថាជាឱវាទ) ១០ សូម្បីឲ្យក្រៃលែងឡើងទៅទៀត ដោយពាក្យថា **សូមទ្រង់ប្រព្រឹត្តធម៌ចុះ** ដូច្នេះ ។ សេចក្តីនៃគាថាទាំងនោះ បានពណ៌នាមកហើយក្នុង**តេសកុណជាតក** (ចត្តាលីសនិបាត) ខាងក្រោយ ។

កាលអភិបារកសេនាបតី សម្តែងធម៌ ដល់ព្រះរាជាយ៉ាងនេះហើយ ព្រះរាជា ក៏បានបន្ទោបង់ចិត្តប្រតិព័ទ្ធនាងឧម្មាទន្តី ។

ព្រះសាស្តា នាំព្រះធម្មទេសនានេះ មកហើយទ្រង់ប្រកាសអរិយសច្ចៈ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ភិក្ខុនោះ បានតាំងនៅក្នុងសោតាបត្តិផល ។

**តទា សុនក្ខសារថិ អានន្ទោ អហោសិ** *សុនន្ទសារថីក្នុងកាលនោះបានមកជាអានន្ទ*

**អភិចារកោ សារិបុត្តោ** *អភិបារកៈបានមកជាសារីបុត្រ*

**ឧម្មាទន្តី ឧប្បលវណ្ណា** *នាងឧម្មាទន្តីបានមកជាឧប្បលវណ្ណា*

**សេសបរិសា ពុទ្ធបរិសា** *បរិស័ទដ៏សេសបានមកជាពុទ្ធបរិស័ទ*

**សិវិរាជា អហមេវ អហោសិំ** *ចំណែកព្រះបាទសិវិរាជ គឺ តថាគត នេះឯង ។*

*ឧម្មាទន្តីជាតក ចប់ ។*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ញាសនិបាត បិដកលេខ ៦១ ទំព័រ ១៤)*

*ថ្ងៃ អង្គារ ១១ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ០៧ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ*